ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ : ១៩១ ក.ប/ប្រ.ក

# ប្រកាស
# ស្តីពី
# ការប្រើប្រាស់ហត្ថពលកម្មបរទេស

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នសរកម/០៣៩៧/០០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នសរកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញប្រកាសរួមលេខ ១០០៩ សហវ-ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- តាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**ប្រការ១.-**

ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានទាំងឡាយ ដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ នៅពេលដែលត្រូវការជ្រើសរើសកម្មករនិយោជិត ត្រូវធ្វើការជ្រើសរើសជនជាតិខ្មែរជាអាទិភាព។

ក្នុងករណីដែលមិនអាចរកបាននូវជនជាតិខ្មែរ ដើម្បីបំពេញតាមសេចក្តីត្រូវការចាំបាច់ណាមួយ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន អាចធ្វើការជ្រើសរើសហត្ថពលកម្មបរទេស



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

ដែលជាអ្នកឯកទេស អ្នកបច្ចេកទេស ឬអ្នកមានជំនាញវិជ្ជាជីវៈ សម្រាប់ចូលបម្រើការងារនៅកន្លែងដែលរកហាត្ថពលកម្មខ្មែរមិនបាននោះ ដោយត្រូវធ្វើសំណើជាលាយលក្ខណ៍ អក្សរស្នើសុំការអនុញ្ញាតជាមុនមកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

សំណើស្តីពីសេចក្តីត្រូវការហាត្ថពលកម្មបរទេសសម្រាប់ឆ្នាំបន្ត ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ដាច់ពីគ្នានូវចំនួនកម្មករនិយោជិតខ្មែរ និងបរទេសដែលមានបច្ចុប្បន្ន និងមូលហេតុចម្បងដែលនាំឱ្យមានសេចក្តីត្រូវការប្រើប្រាស់ហាត្ថពលកម្មបរទេសនោះ ហើយត្រូវផ្ញើមកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឱ្យបានមុនដំណាច់ខែ វិច្ឆិកា នៃឆ្នាំនីមួយៗ។

**ប្រការ២.-**

ផ្អែកតាមសំណើរបស់ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាននីមួយៗ ជាទូទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងអនុញ្ញាតឱ្យប្រើប្រាស់ហាត្ថពលកម្មបរទេស មិនលើសពី១០%នៃចំនួនកម្មករនិយោជិតខ្មែរសរុបទេ។ អត្រាកំណត់អតិបរមា ១០% នេះ បែងចែកទៅតាមប្រភេទនៃកម្មករនិយោជិត ដូចខាងក្រោម៖

- និយោជិតការិយាល័យ ៣ ភាគរយ
- និយោជិត ឬកម្មករឯកទេស ៦ ភាគរយ
- និយោជិត ឬកម្មករគ្មានឯកទេស ១ ភាគរយ

ក្នុងករណីដែលសេចក្តីត្រូវការប្រើប្រាស់ហាត្ថពលកម្មបរទេសលើសពីអត្រា ១០% សំណើសុំការអនុញ្ញាតនេះត្រូវបញ្ជាក់ឱ្យបានលម្អិត និងច្បាស់លាស់ អំពីមុខងារមុខវិជ្ជាឯកទេស បច្ចេកទេស ឬមុខជំនាញវិជ្ជាជីវៈនៃជនបរទេសម្នាក់ៗ ដែលត្រូវធ្វើការជ្រើសរើសចូលបម្រើការងារ និងមូលហេតុជាក់ស្តែង ដែលនាំឱ្យមានសេចក្តីត្រូវការប្រើប្រាស់ហាត្ថពលកម្មបរទេសម្នាក់ៗ ដែលលើសអត្រា១០%នោះ។

**ប្រការ៣.-**

ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ដែលមានប្រើប្រាស់ជនបរទេស ត្រូវយកកិច្ចសន្យាការងារជាលាយលក្ខណ៍អក្សររបស់ជនបរទេសម្នាក់ៗ មកចុះបញ្ជិកានៅនាយកដ្ឋានមុខរបរ និងហាត្ថពលកម្ម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំពោះអ្នកនៅរាជធានីភ្នំពេញ និងចុះបញ្ជិកានៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត ចំពោះអ្នកនៅរាជធានី-ខេត្ត។

**ប្រការ៤.-**

អ្នកប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ នឹងត្រូវពិន័យ ឬទទួលទោសដូចមានចែងក្នុងជំពូក១៦ នៃច្បាប់ស្តីពីការងារ។

**ប្រការ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គាធិការនៃអគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**__កន្លែងទទួល:__**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៦
  "ដើម្បីអនុវត្ត"
- ឯកសារ -កាលប្បវត្តិ

......ក្បាលលិខិតរបស់សហគ្រាស គ្រឹះស្ថាន......

**នាយកសហគ្រាស គ្រឹះស្ថាន**..............................

**សូមគោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**កម្មវត្ថុ៖** សំណើសុំកូតា (quota) ប្រើប្រាស់ហត្ថពលកម្មបរទេសចំនួន............នាក់ សម្រាប់ឆ្នាំ.........

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមគោរព និងជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា នៅក្នុងឆ្នាំ............... ខាងមុខនេះ សហគ្រាស គ្រឹះស្ថាន................................ .............យើងខ្ញុំនឹងត្រូវការប្រើប្រាស់ហត្ថពលកម្មបរទេសជាសរុបចំនួន..............នាក់ ដោយមូលហេតុ ..........................................................................................................................................។

ចំពោះហត្ថពលកម្មបរទេស ដែលនឹងត្រូវការប្រើប្រាស់នាឆ្នាំ........... ចំនួន...........នាក់នេះ គឺមានចំនួន........នាក់ ដែលបាននឹងកំពុងបំរើការងារក្នុងក្រុមហ៊ុនយើងខ្ញុំក្នុងឆ្នាំ..........កន្លងមក។

ដូច្នេះយើងខ្ញុំសូមស្នើសុំបន្ថែម ឬរក្សាហត្ថពលកម្មបរទេសចំនួន.....នាក់ទៀត ឬនៅដដែល។ (សូមមេត្តាពិនិត្យតារាងស្នើសុំប្រើប្រាស់ហត្ថពលកម្មបរទេស ជូនភ្ជាប់មកជាមួយ)។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើនេះ ខ្ញុំបាទសូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេច ផ្តល់ការអនុញ្ញាតឱ្យប្រើប្រាស់ហត្ថពលកម្មបរទេសសម្រាប់ឆ្នាំ............ចំនួន..........នាក់ ដល់ក្រុមហ៊ុនយើងខ្ញុំ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៤

**នាយកក្រុមហ៊ុន**.........................

.....ក្បាលលិខិតរបស់សហគ្រាស គ្រឹះស្ថាន.....

# **តារាងស្នើសុំកូតា** ( quota ) **ប្រើប្រាស់ហត្ថពលកម្មបរទេស**
# **សម្រាប់ឆ្នាំ**...............

| ល.រ | ផ្នែកការងារ និង ភារកិច្ច | ចំនួនកម្មករ និយោជិតខ្មែរ | | | ចំនួនហត្ថពលកម្មបរទេស | | | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | បច្ចុប្បន្ន | ត្រូវការបន្ថែម | សរុប | បច្ចុប្បន្ន | ត្រូវការបន្ថែម | សរុប | |
| 1 | 2 | 3 | 4 | 5 = 3 + 4 | 6 | 7 | 8 = 6 + 7 | 9 |
| | **ក-រដ្ឋបាលគ្រប់គ្រង** | | | | | | | |
| ១ | នាយក-នាយករង | | | | | | | |
| ២ | រដ្ឋបាល-គណនេយ្យ | | | | | | | |
| ៣ | .......................... | ........ | | ........ | ........ | | ........ | |
| | **ខ-ផ្នែក**................ | | | | | | | |
| ៤ | .......................... | ........ | | ........ | ........ | | ........ | |
| ៥ | | | | | | | | |
| ៦ | | | | | | | | |
| | **គ-ផ្នែក**................ | | | | | | | |
| ៧ | .......................... | ........ | | ........ | ........ | | ........ | |
| ........ | | | | | | | | |
| ........ | | | | | | | | |
| ........ | | | | | | | | |
| **សរុប** | | | | | | | | |

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០

**នាយកក្រុមហ៊ុន**...................................

